# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០ អនក្រ

## សេចក្តីសំរេច

## ស្តីពី

## ការទប់ស្កាត់អំពើអនាធិបតេយ្យនៅ

## តំបន់ឆ្នេរសមុទ្រ ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុសាសន៍សម្តេចនាយករដ្ឋមន្ត្រី ឆ្នាំ ២០០០ សំរាប់ប្រជាជនដែលរស់នៅតំបន់ទំនប់រលក
- យោងកំណត់ហេតុអង្គប្រជុំគណៈកម្មាធិការអន្តរក្រសួង និង គណៈកម្មាធិការរៀបចំសោភ័ណភាពក្រុង ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
- ដើម្បីធានាការគ្រប់គ្រង និង ប្រើប្រាស់តំបន់ឆ្នេរសមុទ្រអោយមានចីរភាព

## សំរេច

**ប្រការ ១** : ត្រូវបញ្ឈប់ជាបន្ទាន់ នូវសកម្មភាពបំពានច្បាប់នៅតំបន់ឆ្នេរសមុទ្រក្រុងព្រះសីហនុ ដែលបានបង្កការប៉ះពាល់បំផ្លិចបំផ្លាញបរិស្ថាន និង ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ នៅតាមចំណុចដូចខាងក្រោម ៖

១_ការចាក់ដីចូលសមុទ្រ ០២ កន្លែង នៅតំបន់ឆ្នេររាម ភូមិអុង សង្កាត់រាម ខ័ណ្ឌព្រៃនប់ ។

២_ការចាក់ដីចូលសមុទ្រនៅភូមិទំនប់រលក (តំបន់ឡូទីកត្រី) ត្រង់ចំណុច $A_1$ $A_2$ $A_3$ $A_4$ តាមប្លង់របស់ក្រុមការងារសាលាក្រុងព្រះសីហនុ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ និង ០១ កន្លែងនៅតំបន់ឆ្នេរព្រែកត្រែង (ទល់មុខស្ថានីយ៍បូមទឹក) ។

**ប្រការ ២** : ចំពោះដីដែលបានចាក់ចូលសមុទ្រទាំងអស់ ដូចបានរៀបរាប់ក្នុងប្រការ ១ ខាងលើ អាជ្ញាធរក្រុងព្រះសីហនុត្រូវគ្រប់គ្រងដីនោះទុកប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ ត្រូវសហការអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ_កាលប្បវត្តិ*